ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍
ចូល
លេខ ៥៧៤
ថ្ងៃទី ៥ ខែ ៣ ឆ្នាំ២០២៥
ម៉ោង ១២:០០
បញ្ជូន

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**

លេខ: ៣៦១ សជណ.ចប

ថ្ងៃ ពុធ ៧កើត ខែ ផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ៥ ខែមីនា ឆ្នាំ២០២៥

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**សូមជម្រាបជូន**

- **ឯកឧត្តមបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**
- **ឯកឧត្តមរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍**

**កម្មវត្ថុ៖** ករណីរបាយការណ៍ស្តីពីការពិភាក្សាលើការរៀបចំលិខិតបទដ្ឋានគតិយុត្ត កំណត់អំពីយន្តការគ្រប់គ្រងវិជ្ជាជីវៈវិស័យឌីជីថលនៅកម្ពុជា និងសំណើគោរពសុំគោលការណ៍លើការងារបន្ត។

**យោង ៖**
- លិខិតលេខ៥២៧ អយក.រប ចុះថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០២៥ របស់ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- ចំណារដ៏ខ្ពង់ខ្ពស់បំផុតរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៥។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ទីស្តីការគណៈរដ្ឋមន្ត្រីសូមជម្រាបជូនឯកឧត្តមមេត្តាជ្រាបថា រាជរដ្ឋាភិបាលយល់ព្រមជាគោលការណ៍ ដូចខាងក្រោម៖

១- អនុញ្ញាតឱ្យក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ រៀបចំអនុក្រឹត្យស្តីពីការគ្រប់គ្រងវិជ្ជាជីវៈវិស័យឌីជីថល ដោយក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ មានសិទ្ធិវាយតម្លៃគ្រឹះស្ថានជាតិនិងអន្តរជាតិ និងឯកសារបញ្ជាក់គុណវុឌ្ឍិវិជ្ជាជីវៈដែលអាចប្រើប្រាស់ សម្រាប់ទទួលស្គាល់គុណវុឌ្ឍិវិជ្ជាជីវៈនៅកម្ពុជា។

២- អនុញ្ញាតឱ្យក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការរៀបចំក្របខ័ណ្ឌគុណវុឌ្ឍិវិជ្ជាជីវៈវិស័យឌីជីថល ដើម្បីត្រួតពិនិត្យវាយតម្លៃ និងគាំទ្រដល់កម្មវិធីសិក្សាពាក់ព័ន្ធនៅតាមគ្រឹះស្ថានបណ្តុះបណ្តាល។

៣- អនុញ្ញាតឱ្យក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ចាប់ផ្តើមដំណើរការរៀបចំបង្កើតសមាគមឬសង្គមអ្នកវិជ្ជាជីវៈវិស័យឌីជីថល (Digital Professionals Association or Society) ស្របតាមនីតិវិធីជាធរមាន និងផ្សព្វផ្សាយកៀរគរអ្នកប្រកបវិជ្ជាជីវៈវិស័យឌីជីថលឱ្យចូលរួមជាសមាជិក និងចូលរួមនៅក្នុងគណៈគ្រប់គ្រងនៃសមាគមឬសង្គម ដោយមានការចូលរួមពីក្រសួងអប់រំ យុវជន និងកីឡា។

៤- អនុញ្ញាតឱ្យក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងក្រសួងអប់រំ យុវជន និងកីឡា ផ្សព្វផ្សាយអំពីទស្សនទាននៃការរៀបចំយន្តការគ្រប់គ្រងវិជ្ជាជីវៈវិស័យឌីជីថល និងអត្ថប្រយោជន៍នៃការចូលរួមក្នុងយន្តការនេះ ទៅកាន់ប្រតិបត្តិករក្នុងវិស័យឌីជីថល អ្នកប្រកបវិជ្ជាជីវៈវិស័យឌីជីថល បុគ្គលិកអប់រំដែលមានជំនាញឌីជីថលក្នុងប្រព័ន្ធអប់រំ ដើម្បីកៀរគរឱ្យមានការចូលរួមកាន់តែទូលំទូលាយ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមមេត្តាជ្រាបនិងចាត់ចែងអនុវត្ត។

**ជ. រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**រដ្ឋលេខាធិការ**

**ហ៊ុយ វណ្ណៈ**

**ចម្លងជូន៖**
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ
- ឯកសារ កាលប្បវត្តិ